ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៣៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់និងការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២០២ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរស័ក្តិមន្ត្រីពន្ធនាគារជាមួយនឹងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិល និង មន្ត្រីនគរបាលជាតិ និង ការធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា១.-

អនុក្រឹត្យនេះ មានគោលបំណងដើម្បីរៀបចំការកំណត់និងការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

www.pheakdeylaw.com

មាត្រា២ .-

អនុក្រឹត្យនេះ មានគោលដៅកំណត់៖

- កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- ការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

មាត្រា៣ .-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីពន្ធនាគារដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ។

មាត្រា៤ .-

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីពន្ធនាគារដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ។

បៀវត្សមូលដ្ឋានរបស់មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃឋានន្តរស័ក្តិ និងត្រូវបានផ្តល់នូវកម្រិតសន្ទស្សន៍ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

ល.រ	ឋានន្តរស័ក្តិ	កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋាន
១	ឧត្តមអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ១	៥៣១
២	ឧត្តមអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ២	៥១៣
៣	ឧត្តមអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ៣	៤៩៦
៤	វរអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ១	៤៧៩
៥	វរអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ២	៤៦១
៦	វរអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ៣	៤៤៣
៧	អគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ១	៤០៧
៨	អគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ២	៣៨០
៩	អគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ៣	៣៤៤
១០	អគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ៤	៣៣១
១១	អនុរក្សពន្ធនាគារ ថ្នាក់លេខ១	៣១៨
១២	អនុរក្សពន្ធនាគារ ថ្នាក់លេខ២	៣០០
១៣	អនុរក្សពន្ធនាគារ ថ្នាក់លេខ៣	២៨៤

កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានខាងលើ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

មាត្រា៥ .-

តម្លៃឯកតាសន្ទស្សន៍សម្រាប់អនុវត្តនិងការកែប្រែតម្លៃឯកតាសន្ទស្សន៍ ត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីតម្លៃឯកតានៃសន្ទស្សន៍សម្រាប់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

មាត្រា៦ .-

មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃដែលមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ និងរបបអង្គប្រចាំខែ ព្រមទាំងរបបឧបត្ថម្ភផ្សេងទៀត ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

www.pheakdeylaw.com

- កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈឬបច្ចេកទេសតាមតម្រូវការរបស់រដ្ឋ
- កំពុងបំពេញកម្មសិក្សាជាដំបូងដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌ
- កំពុងបំពេញការងារក្នុងក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែង
- កំពុងបំពេញការសិក្សាក្នុង ឬ ក្រៅប្រទេសតាមតម្រូវការរបស់ក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- មន្ត្រីពន្ធនាគារពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- មន្ត្រីពន្ធនាគារដែលទទួលការអនុញ្ញាតច្បាប់ក្នុងចុះផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

មាត្រា៧ .-

ការបញ្ឈប់ការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ និងរបបអង្គរប្រចាំខែ ព្រមទាំងរបបឧបត្ថម្ភផ្សេងទៀត ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីដូចខាងក្រោម៖

- មន្ត្រីពន្ធនាគារសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីពន្ធនាគារដែលមានប្រកាសបណ្តេញចេញពីក្របខណ្ឌមន្ត្រីពន្ធនាគារ
- មន្ត្រីពន្ធនាគារដែលអវត្តមានគ្មានការអនុញ្ញាត ឬ ហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- មន្ត្រីពន្ធនាគារពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- មន្ត្រីពន្ធនាគារដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត។

មាត្រា៨ .-

ប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារ ដែលកំពុងបើកផ្តល់បច្ចុប្បន្ន ព្រមទាំងប្រាក់បន្ទាប់បន្សំផ្សេងទៀតនៃបៀវត្សនិងរបបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីពន្ធនាគារ ក្រៅពីបៀវត្សមូលដ្ឋាន ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

មាត្រា៩ .-

ការកែប្រែប្រាក់បំណាច់មុខងារ ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីពន្ធនាគារ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

មាត្រា១០ .-

បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ រួមទាំងរបបអង្គរប្រចាំខែ ដែលគិតជាសាច់ប្រាក់ត្រូវបើកផ្តល់ដល់មន្ត្រីពន្ធនាគារតាមប្រព័ន្ធធនាគារ។

www.pheakdeylaw.com

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវសហការរៀបចំការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ រួមទាំងរបបអង្គរប្រចាំខែគិតជាសាច់ប្រាក់ដល់មន្ត្រីពន្ធនាគារតាមប្រព័ន្ធធនាគារឱ្យបានរួចរាល់ក្នុងឆ្នាំ២០១៥។

ក្នុងករណីសេវាធនាគារមិនទាន់មាននៅជិតអង្គភាព ដើម្បីបង្កភាពងាយស្រួលដល់ការបើកផ្តល់បៀវត្សដល់មន្ត្រីពន្ធនាគារម្នាក់ៗ ក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសារាចរណែនាំស្តីពីការបើកផ្តល់បៀវត្សពីធនាគារដល់មន្ត្រីពន្ធនាគារនៅតាមអង្គភាពនោះ។

មាត្រា១១ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**	**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**	**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
ស ខេង	**អូន ព័ន្ធមុនីរ័ត្ន**	**ពេជ្រ ប៊ុនធិន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com